ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៖ ៣៥..សសរ

# សេចក្តីសម្រេច

## ស្តីពីការបង្កើតគណៈកម្មការចំរុះដើម្បីបង្ក្រាបការលេងល្បែង ឆ្នោត-ឡូតូ ភ្នាល់បាល់ ល្បែងកំសាន្តស្លុតម៉ាស៊ីន និងបនល្បែងស៊ីសងខុសច្បាប់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ខែកក្កដាឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ខែកក្កដាឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីណែនាំលេខ០១ សណន ចុះថ្ងៃទី២០ខែមេសាឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាល ស្តីពីសកម្មភាពមជ្ឈមណ្ឌលកំសាន្ត ឬក្លឹបកំសាន្តដែលមានបំពាក់ម៉ាស៊ីនអេឡិចត្រូនិចនិងមេកានិចគ្រប់ប្រភេទ
- យោងតាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១** ៖ បង្កើតគណៈកម្មការចំរុះដើម្បីបង្ក្រាបការលេងល្បែងឆ្នោត-ឡូតូ ភ្នាល់បាល់ ល្បែងកំសាន្តស្លុតម៉ាស៊ីន និងបនល្បែងស៊ីសងខុសច្បាប់ ដែលមានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| - ឯកឧត្តម ជា ប៉េងឈាង | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាប្រធាន |
| - ឯកឧត្តម នាយឧត្តមសេនីយ៍ ឯម សំអាន | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ជាអនុប្រធាន |
| - ឯកឧត្តម ឧត្តមសេនីយ៍ឯក សូ ផន | អគ្គស្នងការរងទី១នគរបាលជាតិ | ជាសមាជិក |
| - ឯកឧត្តម ឧត្តមសេនីយ៍ឯក សុខ ផល | អគ្គស្នងការរងនគរបាលជាតិ | ជាសមាជិក |
| - លោក ម៉ី ទ៉ាន់ | ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ (កសហវ) | ជាសមាជិក |

- ឯកឧត្តម ឧត្តមសេនីយ៍ត្រី ង៉ែត ស៊ីណារិទ្ធ ប្រធាននាយកដ្ឋានព័ត៌មានទូទៅ ក្រសួងមហាផ្ទៃ ជាសមាជិក
- លោក រស់ តិរុណ ប្រធានការិយាល័យគ្រប់គ្រងកាស៊ីណូ (កសហវ) ជាសមាជិក
- លោក សេក ស៊ីន ប្រធានការិយាល័យសេវាហិរញ្ញវត្ថុ (កសហវ) ជាសមាជិក
- លោក អ៊ឹម គង់ លេខាផ្ទាល់ ឯ.ឧ រដ្ឋលេខាធិការ (កសហវ) ជាលេខាធិការ

**ប្រការ២ :** គណៈកម្មការចំរុះដើម្បីបង្ក្រាបការលេងល្បែងឆ្នោត-ឡូតូ ភ្នាល់ចាល់ ល្បែងកំសាន្តស្លុតម៉ាស៊ីន និងបនល្បែងស៊ីសងខុសច្បាប់ មានតួនាទីនិងភារកិច្ច ដូចខាងក្រោម:

១. សហការក្នុងការការពារសិទ្ធិធ្វើអាជីវកម្មស្របច្បាប់របស់ក្រុមហ៊ុនទាំងឡាយ កំពុងប្រកបអាជីវកម្ម ឆ្នោត-ឡូតូ ភ្នាល់ចាល់ និងល្បែងកំសាន្តស្លុតម៉ាស៊ីន ដែលបានទទួល ការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាល ការបញ្ជាក់ទីតាំងពីសាលាខេត្ត-ក្រុង និងអាជ្ញាប័ណ្ណពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

២. ចាត់វិធានការបង្ក្រាប និងលុបបំបាត់ការធ្វើអាជីវកម្ម ឆ្នោត-ឡូតូ ភ្នាល់ចាល់ ល្បែងកំសាន្តស្លុតម៉ាស៊ីន ដោយគ្មាន ការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាល ការបញ្ជាក់ទីតាំងពីសាលាខេត្ត-ក្រុង និងដោយគ្មានអាជ្ញាប័ណ្ណពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមទាំងបនល្បែងស៊ីសងខុសច្បាប់ ដែលបានធ្វើឱ្យខាតបង់ចំណូលថវិកាជាតិ និងធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម។

**ប្រការ៣ :** គណៈកម្មការចំរុះដើម្បីបង្ក្រាបការលេងល្បែងឆ្នោត-ឡូតូ ភ្នាល់ចាល់ ល្បែងកំសាន្តស្លុតម៉ាស៊ីន និងបនល្បែងស៊ីសងខុសច្បាប់មានសិទ្ធិបង្កើតអនុគណៈកម្មការចំរុះនៅតាមខេត្ត-ក្រុង សំរាប់ធ្វើប្រតិបត្តិការបង្ក្រាបការលេងល្បែងស៊ីសងខុសច្បាប់នេះ នៅតាមខេត្ត-ក្រុង ដែលមានសមាសភាព :

- ឯកឧត្តម អភិបាល ឬអភិបាលរងខេត្ត-ក្រុង ជាប្រធាន
- តំណាង នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ (កសហវ) ជាអនុប្រធាន
- តំណាង ស្នងការនគរបាលខេត្ត-ក្រុង ជាសមាជិក
- តំណាង អង្គភាពជំនាញ នៃសាលាខេត្ត-ក្រុង ជាសមាជិក
- ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត-ក្រុង ជាសមាជិកនិងជាលេខាអចិន្ត្រៃយ៍

**ប្រការ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាមីខ្លួនដែលមានចែងក្នុងប្រការមួយ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពី ថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០០៥

ហ៊ុន សែន

__ចំលងជូន:__

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-សាលាខេត្ត-ក្រុង ដែលពាក់ព័ន្ធ
-ដូចប្រការ៤
-ឯកសារ-កាលប្បវត្តិ